**UNITED NATIONS**
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

OHCHR

# ទិវាអន្តរជាតិស្តីពីជនជាតិដើមភាគតិចក្នុងពិភពលោក

ថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៦

ថ្ងៃនេះយើងទាំងអស់គ្នាប្រារព្ធទិវារំលឹកខួបលើកទី១២ នៃទិវាអន្តរជាតិស្តីពីជនជាតិដើមភាគតិចក្នុងពិភពលោក ។

ពិធីរំលឹកខួបឆ្នាំនេះ មានសារៈសំខាន់ជាពិសេស ដោយមានការអនុម័តនាពេលថ្មីៗនេះ នូវសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០០៦ ។ នៅពេលដែលសេចក្តីប្រកាសនេះត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីប្រកាស និង អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ ស្តីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធ នឹងក្លាយជាឯកសារអន្តរជាតិដ៏សំខាន់សំរាប់ការពារ និងធានាសិទ្ធិជនជាតិដើមភាគតិច ។

សេចក្តីប្រកាសទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិចលើដីធ្លី និងធនធានធម្មជាតិទាំងអស់ ដែលពួកគេបានគ្រប់គ្រងកាន់កាប់ ឬប្រើប្រាស់ជាប្រពៃណី និងតម្រូវឱ្យរដ្ឋនានា ការពារ និងទទួលស្គាល់សិទ្ធិស្របច្បាប់លើដីធ្លី និងធនធានធម្មជាតិទាំងនេះ ។ ម្យ៉ាងវិញទៀត អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ អំពាវនាវឱ្យរដ្ឋាភិបាលនានា កំណត់អត្តសញ្ញាណដីធ្លីដែលជនជាតិដើមភាគតិចបានគ្រប់គ្រងជាប្រពៃណី និងដើម្បីធានាការពារយ៉ាងមានប្រសិទ្ធភាពចំពោះសិទ្ធិកម្មសិទ្ធិ និងសិទ្ធិកាន់កាប់របស់ពួកគេ ។

ច្បាប់ភូមិបាលកម្ពុជា ឆ្នាំ២០០១ ទទួលស្គាល់សិទ្ធិសហគមន៍ជនជាតិដើមភាគតិចលើកម្មសិទ្ធិដីសមូហភាពរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព និងការការពារដីជនជាតិដើមភាគតិច ក្នុងអំឡុងពេលរង់ចាំការចុះបញ្ជី នៅមិនទាន់បានអនុម័តនៅឡើយ ។

ដូចតំណាងពិសេសនានា នៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបញ្ជាក់ថា ជនជាតិដើមភាគតិចកំពុងទទួលរងគ្រោះកាន់តែខ្លាំងឡើងៗ ដោយសារការដកហូតយកដីធ្លី ការលក់ ឬការផ្ទេរប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ពួកគេ ។ លោកមានការព្រួយបារម្ភយ៉ាងខ្លាំងថា នៅពេលដែលបទបញ្ញត្តិសំរាប់អនុវត្តច្បាប់ទាំងនេះត្រូវបានអនុម័ត នោះដីសំរាប់ផ្តល់កម្មសិទ្ធិសមូហភាពនឹងមាននៅសល់តិចតួចណាស់ ។ គេត្រូវការឱ្យមានជាបន្ទាន់នូវបទបញ្ញត្តិនេះ និងវិធានការបណ្តោះអាសន្នមួយចំនួន ដើម្បីការពារដីស្របច្បាប់សំរាប់ផ្តល់កម្មសិទ្ធិដល់ជនជាតិដើមភាគតិច ។

ក្នុងករណីដែលដីធ្លី និងធនធានធម្មជាតិនានារបស់ជនជាតិដើមភាគតិច ត្រូវបានគេរឹបអូស លក់ ឬផ្ទេរ ប័ណ្ណកម្មសិទ្ធិ ឬកាន់កាប់ដោយមិនប្រាប់ឱ្យដឹង និងមិនមានការយល់ព្រមដោយសេរីជាមុនទេនោះ រដ្ឋត្រូវចាត់វិធានការដោះស្រាយបញ្ហាទាំងនេះ ។ សិទ្ធិដោះស្រាយនេះ ត្រូវបានទទួលស្គាល់នៅក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលបានអំពាវនាវសុំឱ្យដោះស្រាយប្រគល់ដីធ្លី និងធនធានដែលមានបញ្ហាទាំងនេះឱ្យពួកគេវិញ ឬផ្តល់ដីធ្លី និងធនធានផ្សេងទៀតដែលមានគុណភាព ទំហំ និងស្ថានភាពដីដូចគ្នា ។

នៅក្នុងឱកាសទិវាអន្តរជាតិស្តីពីជនជាតិដើមភាគតិចនាថ្ងៃនេះ យើងខ្ញុំសូមវាយតំលៃខ្ពស់ចំពោះការរីកចំរើនមកដល់ពេលនេះ និងអាចឱ្យប្រទេសកម្ពុជាធ្វើការប្តេជ្ញាចិត្តជាថ្មី ដើម្បីបង្កើត និងអនុវត្តគោលនយោបាយជាតិឱ្យមានប្រសិទ្ធភាព ដើម្បីគោរពអត្តសញ្ញាណ វប្បធម៌ និងរបៀបរបបរស់នៅរបស់ជនជាតិដើមភាគតិច និងពង្រឹងការអនុវត្តន៍សិទ្ធិរបស់ពួកគេ ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាសង្ឃឹមថា នឹងធ្វើការជាមួយរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល ទីភ្នាក់ងារអន្តរជាតិ និងជនជាតិដើមភាគតិចកម្ពុជា ដើម្បីសំរេចគោលដៅនេះ ។

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org